# សេចក្តីថ្លែងការណ៍រួម

អង្គការពលកម្មអន្តរជាតិ (ILO) និង
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំនៅកម្ពុជា

**អង្គការពលកម្មអន្តរជាតិ (ILO) និង ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) សំដែងការស្វាគមន៍ចំពោះសេចក្តីសំរេចរបស់តុលាការកំពូល ក្នុងការបង្គាប់ឲ្យបើកការស៊ើបអង្កេតជាថ្មី លើករណីឃាតកម្មលើលោក រស់ សុវណ្ណារេត ប្រធានសហជីពកម្មករ និង ដោះលែង លោក ថាច់ សាវេត ឲ្យនៅក្រៅឃុំ**

*ភ្នំពេញ ថ្ងៃទី ៤ ខែមីនា ឆ្នាំ ២០១១* - អង្គការពលកម្មអន្តរជាតិ(ILO) និង ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) សំដែងការស្វាគមន៍ចំពោះការសំរេចរបស់តុលាការកំពូលកាលពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១១ ក្នុងការដោះលែង លោក ថាច់ សាវេត ដែលគេស្គាល់ថា ចាន់ សុភ័ក្រ ឲ្យនៅក្រៅឃុំបណ្តោះអាសន្ន និង បង្គាប់ឲ្យសាលាឧទ្ធរណ៍បើកការស៊ើបអង្កេតករណីនេះឡើងវិញ ។

អង្គការ ILO និង ការិយាល័យ OHCHR បានតាមសង្កេតមើលដំណើរការជំនុំជម្រះក្តីនេះយ៉ាងជិតដល់តាំងពីឆ្នាំ២០០៥ រហូតមក ។ លោក ថាច់ សាវេត បានជាប់ពន្ធនាគារជិតប្រាំពីរឆ្នាំមកហើយ ។ គាត់ត្រូវបានតុលាការផ្តន្ទាទោសពីបទឃាតកម្មលើ លោក រស់ សុវណ្ណារេត ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា(FTUWKC) បើទោះជាពុំមានភស្តុតាងគ្រប់គ្រាន់គួរឲ្យជឿបានប្រឆាំងនឹងរូបលោក និង ភាពមិនប្រក្រតីធ្ងន់ធ្ងរផ្នែកនីតិវិធី ក៏ដោយ។

អង្គការ ILO និង ការិយាល័យ OHCHR សូមស្វាគមន៍ផងដែរ ចំពោះការដែលតុលាការកំពូលបានយោងដល់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ(ICCPR) នៅក្នុងសេចក្តីសំរេចរបស់ខ្លួន និង សូមលើកទឹកចិត្តដល់ចៅក្រមនានា ឲ្យទាញយកបទពិសោធន៍ពីសាលដីកាដ៏សំខាន់នេះ សំរាប់ការសំរេចសេចក្តីរបស់ខ្លួន ។ នៅឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញ បានណែនាំថា ក្នុងការសំរេចរបស់ខ្លួន ចៅក្រមនានា អាចអនុវត្តដោយផ្ទាល់នូវរាល់សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងអស់ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន។

សេចក្តីសំរេចរបស់តុលាការកំពូល ឆ្លុះបញ្ចាំងដល់សេចក្តីសំរេចស្រដៀងគ្នាមួយ ដោយតុលាការដដែលនេះ កាលពីឆ្នាំ២០០៨ ដែលនាំឲ្យមានការដោះលែង លោក ប៊ន សំណាង និងលោក សុខ សំអឿន ឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ដែលបុរសទាំងពីរនាក់នេះ បានជាប់ចោទពីបទឃាតកម្មលើ លោក ជា វិជ្ជា ប្រធានសហជីពកម្មករ។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១០ តុលាការកំពូលបានបង្គាប់ផងដែរឲ្យតុលាការថ្នាក់ក្រោមបើកការស៊ើបអង្កេតជាថ្មីលើករណីឃាតកម្មលើលោក ហ៊ី វុទ្ធី។ សេចក្តីសំរេចដ៏សំខាន់ទាំងនេះបញ្ជាក់ជាថ្មី

អំពីតួនាទី និង សារសំខាន់របស់តុលាការកំពូល ថាជាផ្លូវមួយសំរាប់កែតម្រូវការប្រព្រឹត្តខុសឆ្គងនៃប្រព័ន្ធយុត្តិធម៌ និង ដោះស្រាយបណ្ដឹងសើរើចុងក្រោយបំផុតសំរាប់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។

បន្ទុកនាពេលនេះ គឺត្រូវធ្លាក់លើសាលាឧទ្ធរណ៍ និង សាលាដំបូងរាជធានីភ្នំពេញ ក្នុងការបើកការស៊ើបអង្កេតករណីទាំងនេះឲ្យបានហ្មត់ចត់ឡើងវិញ ដើម្បីនាំខ្លួនជនដែលជាឃាតករ និង មេគំនិតពិតប្រាកដទៅតុលាការដើម្បីផ្ដន្ទាទោសទៅតាមច្បាប់ ទោះជាជនទាំងនោះជាអ្នកណាក៏ដោយ។ ធ្វើដូចនេះ អាចពង្រឹងការអនុវត្តន៍នីតិរដ្ឋ និង បង្កើនទំនុកចិត្តរបស់សាធារណជនលើប្រព័ន្ធតុលាការ។ ការនេះអាចដោះស្រាយបញ្ហានិទណ្ឌភាពចំពោះករណីឃាតកម្មលើថ្នាក់ដឹកនាំសហជីពកម្មករនានា និង រួមចំណែកជួយស្ដារសតិអារម្មណ៍របស់កម្មករថា ពួកគេអាចពឹងផ្អែកលើច្បាប់ដើម្បីការពារខ្លួន នៅពេលចូលរួមក្នុងសកម្មភាពសម្ព័ន្ធភាព ក្នុងការលើកកំពស់សិទ្ធិពលកម្ម និង លក្ខខណ្ឌការងារសមរម្យនៅក្នុងរោងកាត់ដេរ។

នៅក្នុងរបាយការណ៍ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ក្នុងខែ កញ្ញា ឆ្នាំ ២០១០ ដែលបានផ្ដោតការវាយតំលៃរបស់លោកលើមុខងាររបស់តុលាការ លោក សុរិយា ស៊ូប៊ែឌី អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានផ្ដល់អនុសាសន៍អំពីវិធានការមួយចំនួន ដែលលោកចាត់ទុកថាអាចប្រឹក្សាយោបល់បាន ដើម្បីពង្រឹងថែមទៀតនូវឯករាជ្យភាព និង បូរណភាពរបស់តុលាការ ក៏ដូចជាស្ដារទំនុកចិត្តរបស់សាធារណជនលើប្រព័ន្ធតុលាការឡើងវិញ។

ចប់

ព័ត៌មានសារតា

**និទណ្ឌភាពនៅតែបន្តមានចំពោះឃាតកម្មលើតំណាងសហជីពនានា**

ចាប់តាំងពីឆ្នាំ២០០៤មក ថ្នាក់ដឹកនាំសហជីពបីរូបត្រូវបានគេធ្វើឃាត ដោយសារតែការលើកស្ទួយសិទ្ធិពលកម្ម និង ការបង្កើនលក្ខខណ្ឌការងារនៅក្នុងរោងចក្រកាត់ដេរនៅកម្ពុជា។ បុរសទាំងបីរូបនោះ បានបំរើការឲ្យសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា(FTUWKC) ដែលជាសហព័ន្ធសហជីពដ៏មានឥទ្ធិពលមួយ តំណាងឲ្យកម្មកររោងចក្រកាត់ដេររាប់ពាន់នាក់។ កៅសិបភាគរយនៃកម្មករទាំងនេះ គឺជាស្ត្រីក្មេងៗមកពីគ្រួសារជនបទក្រីក្រ។ ពួកលោកត្រូវបានគេធ្វើឃាតនៅក្នុងរូបភាពប្រហាក់ប្រហែលគ្នា ដែលបានក្លាយជាទម្លាប់ដោះស្រាយវិវាទនៅកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៩៤ មក ៖ គឺពួកលោកត្រូវបានបាញ់សម្លាប់ ដោយបុរសជិះម៉ូតូពីរនាក់។

លោក **ជា វិជ្ជា** ត្រូវគេធ្វើឃាតកាលបីថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ លោក **រស់ សុវណ្ណារេត** កាលពីថ្ងៃទី៧ ខែមិនា ឆ្នាំ២០០៤ និងលោក **ហ៊ី វុទ្ធី** កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៧។ នគរបាលពុំបានស៊ើបអង្កេតបទឧក្រិដ្ឋទាំងនេះឲ្យបានហ្មត់ចត់នោះទេ រីឯការជំនុំជម្រះនៃបទឃាតកម្មលើរូបលោក ជា វិជ្ជា និង លោក រស់ សុវណ្ណារេត ដោយតុលាការដំបូងរាជធានីភ្នំពេញ និង សាលាឧទ្ធរណ៍ ត្រូវបានធ្វើឲ្យសៅហ្មង ដោយភាពមិនប្រក្រតីដ៏ធ្ងន់ធ្ងរទាក់ទិននឹងការបំពានលើគោលការណ៍ជាមូលដ្ឋានបំផុតនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលនាំឲ្យមានការឃុំខ្លួនប្រកបដោយមន្ទិលនៃបុរសទាំងបីរូបនេះអស់ជាច្រើនឆ្នាំ។ ជនពីររូបក្នុងចំណោមជនជាប់ឃុំទាំងបី គឺលោក **ប៊ន សំណាង** និង **សុខ សំអឿន** ដែលត្រូវបានចោទប្រកាន់ពីបទឃាតកម្មលើលោក ជា វិជ្ជា ត្រូវបានតុលាការកំពូលដោះលែងបណ្ដោះអាសន្ន កាលពីខែធ្នូ ឆ្នាំ២០០៨ បន្ទាប់ពីត្រូវជាប់ឃុំអស់រយៈពេល ៥ ឆ្នាំ។ បុរសទីបី គឺលោក **ថាច់ សារ៉េត** ដែលត្រូវបានចោទប្រកាន់ពីបទឃាតកម្មលើលោក រស់ សុវណ្ណារេត ត្រូវបានបង្គាប់ឲ្យដោះលែងបណ្ដោះអាសន្ន កាលពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១១ បន្ទាប់ពីត្រូវជាប់ឃុំអស់រយៈពេលជាងប្រាំមួយឆ្នាំ។ នៅក្នុងករណីទាំងបីនេះ តុលាការកំពូលបានបង្គាប់ឲ្យតុលាការថ្នាក់ក្រោមបើកការស៊ើបអង្កេតឡើងវិញលើករណីឃាតកម្មទាំងនេះ។

បទឧក្រិដ្ឋទាំងនេះបានជះឥទ្ធិពលយ៉ាងស្រួចស្រាវលើការអនុវត្តន៍សិទ្ធិសេរីភាពនៃការបង្កើតសមាគម និង ការបញ្ចេញមតិនៅកម្ពុជា ព្រមទាំងការអភិវឌ្ឍន៍នៃចលនាពលកម្ម នៅកម្ពុជា។ ការឆ្លើយតប របស់អាជ្ញាធរនគរបាល និងតុលាការ ក៏ដូចជាការស្ទាក់ស្ទើររបស់ពួកគេ ក្នុងការស៊ើបអង្កេត និង ផ្ដន្ទាទោសឲ្យមានប្រសិទ្ធិភាពចំពោះករណីទាំងនេះ បានបណ្ដាលឲ្យមានសតិអារម្មណ៍ជាទូទៅថា អំពើឃាតកម្មទាំងនេះ ត្រូវបានប្រព្រឹត្តឡើងដោយហេតុផលនយោបាយ ថាថ្នាក់ដឹកនាំសហជីព និង តំណាងកម្មករនានា ដែលលើកស្ទួយសិទ្ធិពលកម្មកំពុងដាក់អាយុជីវិតរបស់ពួកគេក្នុងហានិភ័យ និងថា ច្បាប់ពុំបានផ្ដល់កិច្ចការពារដល់ពួកគេទាល់តែសោះ។ ការឃុំខ្លួនជនជាប់ចោទ ខណៈដែលជនដៃដល់ពិតប្រាកដ និង អស់អ្នកដែលជាមេគំនិតនៃបទឧក្រិដ្ឋកម្មទាំងនេះ ក៏ដូចជា អ្នកការពារឧក្រិដ្ឋជនទាំងនោះ កំពង់រស់នៅយ៉ាងមានសេរីភាព គឺជាកត្តារួមចំណែកធ្វើឲ្យ ប្រព័ន្ធយុត្តិធម៌កាន់តែបាត់បង់ភាពគួរឲ្យទុកចិត្ត ហើយនិងធ្វើឲ្យបរិយាកាយនិទណ្ឌភាពចាក់ឫសគល់ កាន់តែជ្រៅ នៅក្នុងករណីនៃបទឧក្រិដ្ឋបែបទាំងនេះ។

**ករណីទី១៖ ឃាតកម្មលើរូបលោក ជា វិជ្ជា**

តុលាការដំបូងរាជធានីភ្នំពេញបានផ្តន្ទាទោសបុរសពីររូប គឺលោក ប៊ិន សំណាង និង សុខ សំអឿន ពីបទឃាតកម្ម បន្ទាប់ពីមានការស៊ើបអង្កេតមិនគ្រប់ជ្រុងជ្រោយរបស់នគរបាល ។ មានហេតុផលយ៉ាងរឹងមាំមួយចំនួន ដើម្បីដាក់ការសង្ស័យទៅលើសុពលភាពនៃការផ្តន្ទាទោសបុរសទាំងពីររូបនេះ។ ចៅក្រមស៊ើបសួរដំបូងបានសំរេចលើកលែងចោទប្រកាន់ចំពោះករណីនេះ ដោយសំអាងថាគ្មានភស្តុតាងគ្រប់គ្រាន់ ប៉ុន្តែចៅក្រមរូបនេះត្រូវបានផ្លាស់ចេញ ហើយករណីនេះត្រូវបានបញ្ជូនឲ្យជំនុំជម្រះឡើងវិញ ។ បុរសទាំងពីររូបនេះត្រូវបានផ្តន្ទាទោស ដោយផ្អែកលើចម្លើយសារភាពដែលក្រោយមកត្រូវបដិសេធទៅវិញ ទោះបីជាមានចំលើយរបស់សាក្សីដោះបន្ទុក និងភស្តុតាងដែលបង្ហាញថាបុរសទាំងពីររូបនោះមិនមែនជាអ្នកទទួលខុសត្រូវក៏ដោយ។ លោក ហេង ពៅ អតីតស្នងការនគរបាលរាជធានីភ្នំពេញ ដែលជាអ្នកស៊ើបអង្កេតលើករណីនេះ ក្រោយមកត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឃាតកម្ម បទឆបោក និង បទបំភិតបំភ័យជាច្រើនករណី។

នៅអំឡុងខែមេសាឆ្នាំ២០០៧ សាលាឧទ្ធរណ៍បានសំរេចដំកល់ការផ្តន្ទាទោសនេះ និងរក្សាទោសជាប់ពន្ធនាគាររយៈពេល ២០ឆ្នាំ ទោះបីជាមានភាពខ្វះចន្លោះនៃការជំនុំជម្រះនៅសាលាដំបូងក្តី។

នៅអំឡុងខែមិថុនា ឆ្នាំ២០០៨ លោកស្រីឧត្តមស្នងការអង្គការសហប្រជាជាតិ តាមរយៈការិយាល័យប្រចាំកម្ពុជា បានដាក់ជូនតុលាការកំពូល ក្នុងនាមជាមិត្តរបស់តុលាការ នូវឯកសារវិភាគផ្លូវច្បាប់ ដើម្បីទាញការយកចិត្តទុកដាក់ចំពោះការរំលោភបំពានយ៉ាងច្រើនពីតុលាការថ្នាក់ក្រោម[1] ទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិជាមូលដ្ឋាន។

នៅថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០០៨ តុលាការកំពូលកម្ពុជាបានចេញដីកាបង្គាប់ឲ្យមានការដោះលែងលោក ប៊ិន សំណាង និង លោក សុខ សំអឿន ឲ្យនៅក្រៅឃុំ ប៉ុន្តែនៅតែដាក់ពួកគេឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការដដែល។ ការដោះលែងពួកគេជាបណ្តោះអាសន្ន ត្រូវបានអង្គការពលកម្មអន្តរជាតិ និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិប្រចាំកម្ពុជា ស្វាគមន៍ថាជាជំហានមួយដ៏មានសារៈសំខាន់ឆ្ពោះទៅរកការធានាបាននូវសុវត្ថិភាពថ្នាក់ដឹកនាំសហជីពកម្មករ និង ឆ្ពោះទៅរកការលើកកំពស់នូវសិទ្ធិសេរីភាពក្នុងការបង្កើតសមាគមនៅកម្ពុជា។ សាលាឧទ្ធរណ៍ត្រូវបានបង្គាប់ឲ្យធ្វើការពិនិត្យឡើងវិញនូវករណីនេះ។

នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ សាលាឧទ្ធរណ៍បានបើកសវនាការរយៈពេលខ្លីមួយ ដើម្បីបង្គាប់ជាផ្លូវការឲ្យធ្វើការស៊ើបអង្កេតករណីប្រឆាំងនឹងលោកប៊ិន សំណាង និង សុខ សំអឿន ឡើងវិញ។ ការដោះ

[1] នៅអំឡុងខែកក្កដាឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញបានសំរេចថា សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដោយសារសន្ធិសញ្ញាទាំងនេះត្រូវបានធានាការពារតាមមាត្រា៣១នៃរដ្ឋធម្មនុញ្ញ បង្កើតបានជាផ្នែកមួយនៃច្បាប់កម្ពុជា។ ហេតុដូច្នេះ តុលាការកំពូល ក៏ដូចជាតុលាការកម្ពុជាទាំងអស់ដែរ ត្រូវមានកាតព្វកិច្ចក្នុងការធានាដល់ការគោរពតាមបទបញ្ញត្តិទាំងឡាយស្តីពីការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ដែលមានចែងនៅក្នុងសន្ធិសញ្ញាទាំងនេះ ហើយត្រូវតែធ្វើការដោះស្រាយនូវការរំលោភបំពានទាំងឡាយពីសំណាក់តុលាការថ្នាក់ក្រោម។

លែងបណ្តោះអាសន្ននៃបុរសទាំងពីររូប ត្រូវបានបន្ត។ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ លោក ប៊ិន សំណាង ត្រូវបានលោកចៅក្រមស៊ើបសួរ តុលាការរាជធានីភ្នំពេញ កោះហៅឲ្យចូលខ្លួនមកធ្វើការសាកសួរ ដែលជាផ្នែកមួយនៃការស៊ើបអង្កេតករណីនេះឡើងវិញរបស់តុលានេះ។

**ករណីទី២៖ ឃាតកម្មលើរូប លោក រស់ សុវណ្ណារេត**

លោក រស់ សុវណ្ណារេត អតីតប្រធានសហជីពនៃសហជីពសេរីកម្មករប្រចាំរោងចក្រ Trinuggal Kormara ត្រូវបានបុរសជិះម៉ូតូពីរនាក់បាញ់ស្លាប់ នៅក្នុងរាជធានីភ្នំពេញ កាលពីថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៤។ ឃាតកម្មលើរូប លោក រស់ សុវណ្ណារេត បានកើតមានឡើងមិនដល់រយៈពេលបួនខែផង បន្ទាប់ពីមានឃាតកម្មស្រដៀងគ្នានេះបានកើតឡើងទៅលើរូប លោក ជា វិជ្ជា។ នៅអំឡុងខែ កុម្ភៈ ឆ្នាំ ២០០៥ លោក ថាច់ សាវេត ត្រូវបានគេរកឃើញថាមានពិរុទ្ធភាពពាក់ព័ន្ធនឹងឃាតកម្មនេះ។ ការស៊ើបអង្កេតដែលធ្វើឡើងដោយមន្រ្តីនគរបាលមានភាពធ្វេសប្រហែសយ៉ាងធ្ងន់ធ្ងរ ។ ការផ្តន្ទាទោសដោយតុលាការរាជធានីភ្នំពេញ ត្រូវបានធ្វើឡើងដោយផ្អែកតែទៅលើចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីដាក់បន្ទុក ដែលនគរបាលបានស្រង់យក ហើយសាក្សីនោះក៏មានវត្តមាននៅក្នុងអង្គសវនាការផងដែរ ប៉ុន្តែមិនត្រូវបានចៅក្រមសាកសួរ និងត្រូវបានសួរដេញដោលឆ្លងនោះទេ ។ សេចក្តីថ្លែងការណ៍ផ្ទាល់របស់ជនជាប់ចោទ ហើយនិងកស្សិណរបស់សាក្សីដោះបន្ទុកដែលបានបញ្ជាក់ថាជនជាប់ចោទពុំបានមានវត្តមាននៅទីកន្លែងកើតហេតុ មិនត្រូវបានចៅក្រមយកមកពិចារណានោះឡើយ ដោយសំអាងហេតុថា ចំលើយទាំងនោះបានមកពីសាច់ញាតិរបស់ជនជាប់ចោទ ។ នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ សាលាឧទ្ធរណ៍បានដំកល់សាលក្រមកំបាំងមុខរបស់សាលាដំបូង ។ ថ្ងៃបន្ទាប់មកទៀត លោក ថាច់ សាវេត បានធ្វើបណ្តឹងសារទុក្ខទៅតុលាការកំពូល ។ នៅថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១១ តុលាការកំពូលបានបើកសវនាការជំនុំជម្រះរឿងក្តីនោះ ហើយបានចេញសាលដីការបស់ខ្លួន នៅថ្ងៃ ទី ២ ខែ មីនា ឆ្នាំ ២០១១ ។

**ករណីទី ៣: ករណីឃាតកម្មលើ លោក ហ៊ី វុទ្ធី**

លោក ហ៊ី វុទ្ធី ប្រធានសហជីពសេរីកម្មករប្រចាំនៅរោងចក្រសាន់តិច ត្រូវបានគេបាញ់សម្លាប់ នៅពេលដែលគាត់ធ្វើដំណើរពីកន្លែងធ្វើការត្រឡប់ទៅផ្ទះ កាលពីថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៧។ មួយឆ្នាំក្រោមមក នគបាលបានប្រកាសថា ការស៊ើបអង្កេតរបស់ខ្លួនមិនអាចសម្រេចបានទេ។ នៅថ្ងៃទី ៥ ខែសីហា ឆ្នាំ ២០០៨ តុលាការរាជធានីភ្នំពេញ បានបញ្ជាក់អំពីការសម្រេចនេះ ហើយក៏បានសម្រេចបិទការស៊ើបអង្កេតដោយសំអាងហេតុថា ខ្លួនមានការលំបាកក្នុងការប្រមូលព័ត៌មាន ទាក់ទងនឹងសារតារបស់ជនល្មើស។ នៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩ ក្រោយពីមេធាវីរបស់ប្រពន្ធ លោក ហ៊ី វុទ្ធី បានដាក់បណ្តឹងឧទ្ធរណ៍ សាលាឧទ្ធរណ៍ បានបើកសាវនាការលើករណីនេះ ហើយក៏បាន សម្រេចដំកល់សេចក្តីសម្រេចរបស់តុលាការដំបូងរាជធានីភ្នំពេញ ដើម្បីបិទសំណុំរឿង។ លោកមេធាវីក៏ប្តឹងសារទុក្ខទៅតុលាការកំពូល។ នៅថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១០ តុលាការកំពូលក៏សម្រេចបង្គាប់ឲ្យបើកការស៊ើបអង្កេតឡើងវិញ បន្ទាប់ពីតុលាការដំបូង និងសាលាឧទ្ធរណ៍បានសម្រេចបិទការស៊ើបអង្កេត ដោយសារតែគ្មានភស្តុតាងនោះ។

**ការឆ្លើយតបពីស្ថាប័នអង្គការសហប្រជាជាតិ**

ការសម្លាប់ និង ការគំរាមកំហែងផ្សេងៗ ក៏ត្រូវបានលើកឡើងដោយស្ថាប័នត្រួតពិនិត្យមើលនានារបស់អង្គការពលកម្មអន្តរជាតិ ILO។ អង្គការ ILO បានចុះបំពេញបេសកកម្មទំនាក់ទំនងដោយផ្ទាល់ មកកាន់កម្ពុជាកាលពីខែ មេសា ឆ្នាំ ២០០៨។ បេសកកម្មនោះ បានសន្និដ្ឋានថា ប្រព័ន្ធតុលាការកម្ពុជា ត្រូវបានទទួលរងនូវបញ្ហាជាច្រើនយ៉ាងធ្ងន់ធ្ងរទាក់ទងនឹងសមត្ថភាព និង កង្វះឯករាជ្យភាព ដោយថាការផ្តន្ទាទោសឈ្មោះ ប៊ន សំណាង និង សុខ សំអឿន ត្រូវបានតំកល់នៅក្នុងសារនាការមួយ ដែលគេសង្កេតឃើញថា មានភាពមិនប្រក្រតីខាងនីតិវិធីជាច្រើន រាប់បញ្ចូលទាំងការបដិសេធមិនទទួលយកភស្តុតាងបញ្ជាក់អំពីនិរទោសរបស់ពួកគេ និង ថារដ្ឋាភិបាល មិនបានចាត់វិធានការជាក់លាក់ណាមួយ ដើម្បីធានាឲ្យមានការត្រួតពិនិត្យមើលទៅលើករណីទាំងនេះប្រកបដោយអត្តន័យ និង ឯករាជ្យឡើយ។ អង្គការ ILO ក៏បានកត់សម្គាល់ផងដែរថា ពុំមានការរីកចំរើនណាមួយ ត្រូវបានធ្វើឡើងក្នុងការស៊ើបអង្កេតលើករណីលោក ហ៊ី វុទ្ធី ឡើយ។ ការសន្និដ្ឋានទាំងនេះ ស្របគ្នាទៅនឹង ការសន្និដ្ឋានស្រដៀងគ្នាទាំងឡាយរបស់ លោកតំណាងពិសេសពីរូបរបស់លោកអគ្គលេខាធិការ អ ស ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា គឺលោក ភីធឺ លីប្រិច និង លោក យ៉ាស់ហ្គាយ នៅក្នុងរបាយការណ៍ជាច្រើនរបស់លោក ដែលបានដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស និង អតីតគណៈកម្មាធិការសិទ្ធិមនុស្ស[2]។

នៅក្នុងរបាយការណ៍លើកទី ៣៥១ របស់ខ្លួន គណៈកម្មាធិការអង្គការ ILO ស្តីពីសេរីភាពខាងការបង្កើតសមាគម បានអះអាងសារជាថ្មីអំពីការរកឃើញរបស់បេសកកម្មទំនាក់ទំនងថា រដ្ឋាភិបាលមិនបានចាត់វិធានការជាក់លាក់ណាមួយ ដើម្បីធានាឲ្យមានការត្រួតពិនិត្យទៅលើករណីទាំងឡាយប្រកបដោយអត្តន័យ និងឯករាជ្យឡើយ ហើយបានបង្ហាញការសោកស្តាយចំពោះការខកខានមិនបានអនុវត្តតាមអនុសាសន៍ជាច្រើនរបស់គណៈកម្មាធិការនេះ (កថាខណ្ឌ ២៥២)។

កាលពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ការិយាល័យ OHCHR បានស្វាគមន៍ជាសាធារណៈចំពោះសេចក្តីសម្រេចរបស់តុលាការកំពូល ឲ្យដោះលែងជនទាំងពីររូប គឺឈ្មោះ ប៊ន សំណាង និង សុខ សំអឿន ដែលជាប់ចោទពីបទឃាតកម្មលើលោក ជា វិជ្ជា ហើយបង្គាប់ឲ្យសាលាឧទ្ធរណ៍បើកការស៊ើបអង្កេតករណីនេះ ឡើងវិញ។

កាលពីខែ ឧសភា ឆ្នាំ ២០០៩ នៅក្នុងការអង្កេតឃើញរបស់ខ្លួនទៅលើរបាយការណ៍បឋមរបស់កម្ពុជាស្តីពីការអនុវត្តន៍តាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ របស់អង្គការសហប្រជាជាតិ បានភ្ជាប់ខ្លួនទៅនឹងការរកឃើញ និង អនុសាសន៍របស់អង្គការ ILO ហើយបានជម្រុញរដ្ឋាភិបាលឲ្យធានាថាសមាជិកសហជីពអាចអនុវត្តសិទ្ធិទាំងឡាយរបស់ពួកគេ ដោយគ្មានការភ័យខ្លាច និង ការបំភិតបំភ័យ។

[2] សូមមើល ឧទាហរណ៍ករណីលេខ E/CN.4.2005/116 កថាខណ្ឌ ២២et seq E/CN.4/2005/110 A/HRC/4/36 កថាខណ្ឌ ៩៥ A/HRC/7/42 កថាខណ្ឌ ៥៦។
សូមមើលផងដែរ របាយការណ៍របស់អ្នកតំណាងពិសេសស្តីពី "បែបផែនជាបន្តបន្ទាប់នៃនិទណ្ឌភាព" ដែលមានផ្សព្វផ្សាយនៅលើអាស័យដ្ឋានគេហទំព័ររបស់ការិយាល័យ OHCHR គឺ http://cambodia.ohchr.org

កាលថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ អង្គការ ILO និង ការិយាល័យ OHCHR បានស្វាគមន៍ជាសាធារណៈ ចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ឲ្យបើកការស៊ើបអង្កេតឡើងវិញករណីឃាតកម្មលើ ប្រធានសហជីព ជា វិជ្ជា។

ថ្មីៗបំផុតនេះទៀត កាលពីខែ មិថុនា ឆ្នាំ ២០១០ សន្និសិទស្តីពីពលកម្មអន្តរជាតិ បានពិនិត្យមើលទៅលើការអនុវត្តន៍តាម និង ការការពារសិទ្ធិសេរីភាពខាងការបង្កើតសមាគមរបស់កម្ពុជា ដែលមានចែងក្នុងអនុសញ្ញាឆ្នាំ ១៩៤៨ (លេខ ៨៧) ហើយក៏បានបង្ហាញពីការសោកស្តាយចំពោះកង្វះព័ត៌មានទាក់ទងនឹងការស៊ើបអង្កេតឯករាជ្យ ដែលត្រូវបានរងចាំជាយូរមកហើយ ចំពោះករណីឃាតកម្មលើលោក ជា វិជ្ជា លោក រស់ សុវណ្ណារេត និង ហ៊ី វុទ្ធី។ សន្និសិទបានអំពាវនាវជាថ្មីម្តងទៀតថា សិទ្ធិសេរីភាពខាងការបង្កើតសមាគមរបស់កម្មករ និង និយោជក អាចត្រូវបាន អនុវត្តបាននៅក្នុងបរិយាកាសមួយដែលគ្មានអំពើហឹង្សា ការគាបសង្កត់ និងការគំរាមកំហែងតែប៉ុណ្ណោះ។ សន្និសិទនេះបានជម្រុញឲ្យរដ្ឋាភិបាលបញ្ចប់និទណ្ឌភាព ដោយចាត់វិធានការចាំបាច់ៗជាបន្ទាន់ ដើម្បីឲ្យមានការស៊ើបអង្កេតពេញលេញ និង អព្យាក្រិត្យចំពោះករណីឃាតកម្មលើថ្នាក់ដឹកនាំសហជីពទាំងនេះ ហើយត្រូវនាំខ្លួនមកផ្តន្ទាទោសតាមច្បាប់ មិនត្រឹមតែជនដៃដល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមេគំនិតនៃបទឧក្រិដ្ឋដ៏សាហាវយង់ឃ្នងទាំងនេះផងដែរ ៕